# ថ្នាំវ៉ាក់សាំងជំងឺរាគដោយសារមេរោគរ៉ូតា

## *តើលោកអ្នកត្រូវដឹងអ្វីខ្លះ*

Many Vaccine Information Statements are available in Khmer and other languages. See www.immunize.org/vis

សេចក្តីថ្លែងការណ៍នៃព័ត៌មានអំពីថ្នាំវ៉ាក់សាំងជាច្រើនគឺ អាចរកបានជាភាសាខ្មែរ និងភាសាផ្សេងទៀត។ ចូលមើល www.immunize.org/vis

## 1 ហេតុអ្វីត្រូវចាក់ថ្នាំវ៉ាក់សាំង?

មេរោគរ៉ូតា គឺជាមេរោគ ដែលបណ្តាលឲ្យរាគ ដែលភាគច្រើនកើតឡើងចំពោះទារក និងកុមារ។ រោគរាគអាចធ្ងន់ធ្ងរ ហើយបណ្តាលឲ្យខ្វះជាតិទឹក។ ក្អួត និងគ្រុនក្តៅ ក៏កើតឡើងជាទូទៅ ចំពោះកុមារដែលមានមេរោគរ៉ូតាផងដែរ។

មុនពេលមានថ្នាំវ៉ាក់សាំងជំងឺរាគដោយសារមេរោគរ៉ូតា ជំងឺរាគលើកុមារ គឺជាបញ្ហាសុខភាពទូទៅ និងធ្ងន់ធ្ងរ ចំពោះកុមារនៅសហរដ្ឋអាមេរិក។ កុមារស្ទើរគ្រប់គ្នានៅសហរដ្ឋអាមេរិក ធ្លាក់ឆ្លងមេរោគជំងឺរាគយ៉ាងហោចណាស់មួយដង មុនដល់ថ្ងៃខួបកំណើតអាយុ 5 ឆ្នាំ។

រៀងរាល់ឆ្នាំ មុនពេលមានថ្នាំវ៉ាក់សាំងនេះ៖

- កុមារជាង 400,000 នាក់ ត្រូវទៅជួបវេជ្ជបណ្ឌិត ដើម្បីព្យាបាលជំងឺដែលបង្កឡើងដោយមេរោគរ៉ូតា
- កុមារជាង 200,000 នាក់ ត្រូវបញ្ជូនទៅបន្ទប់សង្គ្រោះបន្ទាន់
- កុមារពី 55,000 ទៅ 70,000 នាក់ ត្រូវដេកសម្រាកពេទ្យ និង
- កុមារ 20 នាក់ 60 បានស្លាប់បាត់បង់ជីវិត។

ចាប់តាំងពីមានថ្នាំវ៉ាក់សាំងជំងឺរាគដោយសារមេរោគរ៉ូតា ករណីដេកសម្រាកពេទ្យ និងទៅបន្ទប់សង្គ្រោះបន្ទាន់ ដោយសារតែមេរោគជំងឺរាគ បានធ្លាក់ចុះយ៉ាងខ្លាំង។

## 2 ថ្នាំវ៉ាក់សាំងជំងឺរាគដោយសារមេរោគរ៉ូតា

មានថ្នាំវ៉ាក់សាំងជំងឺរាគដោយសារមេរោគរ៉ូតាចំនួនពីរម៉ាក។ កូនរបស់លោកអ្នកនឹងទទួលពី 2 ទៅ 3 ដូស ផ្អែកលើថ្នាំវ៉ាក់សាំង ដែលបានប្រើប្រាស់។

ដូសដែលបានណែនាំឲ្យប្រើ នៅអាយុដូចខាងក្រោម៖

- ដូសទីមួយ៖ អាយុ 2 ខែ
- ដូសទីពីរ៖ អាយុ 4 ខែ
- ដូសទីបី៖ អាយុ 6 ខែ (បើចាំបាច់)

កូនរបស់លោកអ្នកនឹងទទួលបានថ្នាំវ៉ាក់សាំងជំងឺរាគដោយសារមេរោគរ៉ូតា ដូសទីមួយ មុនអាយុ 15 សប្តាហ៍ និងដូសចុងក្រោយ នៅមុនអាយុ 8 ខែ។ ថ្នាំវ៉ាក់សាំងជំងឺរាគដោយសារមេរោគរ៉ូតា អាចចាក់ប្រកបដោយសុវត្ថិភាព ក្នុងពេលដំណាលគ្នានឹងថ្នាំវ៉ាក់សាំងដទៃទៀត។

ទារកស្ទើរគ្រប់រូប ដែលទទួលថ្នាំវ៉ាក់សាំងជំងឺរាគលើកុមារ នឹងត្រូវបានការពារប្រឆាំងនឹងរោគរាគធ្ងន់ធ្ងរដែលបង្កដោយមេរោគរ៉ូតា។ ហើយកុមារទាំងនេះភាគច្រើន នឹងមិនរាគដោយសារមេរោគរ៉ូតាឡើយ។

ថ្នាំវ៉ាក់សាំងនឹងមិនបង្ការជំងឺរាគ ឬការក្អួត ដែលបង្កដោយមេរោគដទៃទៀតទេ។

មេរោគមួយទៀត ហៅថាមេរោគ porcine circovirus (ឬធាតុនៃមេរោគ) អាចរកឃើញក្នុងថ្នាំវ៉ាក់សាំងជំងឺរាគដោយសារមេរោគរ៉ូតាទាំងពីរប្រភេទ។ នេះមិនមែនជាមេរោគ ដែលឆ្លងលើមនុស្សទេ ហើយគេមិនដឹងពីហានិភ័យលើសុវត្ថិភាពឡើយ។ សម្រាប់ព័ត៌មានបន្ថែម សូមចូលទៅ **http://wayback.archive-it.org/7993/20170406124518/https:/www.fda.gov/BiologicsBloodVaccines/Vaccines/ApprovedProducts/ucm212140.htm**

## 3 ទារកមួយចំនួនមិនគួរទទួលថ្នាំវ៉ាក់សាំងជំងឺរាគដោយសារមេរោគរ៉ូតានេះឡើយ

ជនណាដែលមានប្រតិកម្មអាឡាក់ស៊ី ចំពោះដូសមុននៃថ្នាំវ៉ាក់សាំងជំងឺរាគដោយសារមេរោគរ៉ូតាដែលគំរាមដល់ជីវិត មិនគួរទទួលដូសមួយទៀតនៃថ្នាំវ៉ាក់សាំងនេះឡើយ។ ទារកដែលមានប្រតិកម្មធ្ងន់ធ្ងរចំពោះធាតុផ្សំនៃថ្នាំវ៉ាក់សាំងជំងឺរាគដោយសារមេរោគរ៉ូតា មិនគួរទទួលថ្នាំវ៉ាក់សាំងទេ។ *សូមប្រាប់វេជ្ជបណ្ឌិតរបស់លោកអ្នក ប្រសិនបើទារករបស់លោកអ្នកមានប្រតិកម្មអាឡាក់ស៊ីធ្ងន់ធ្ងរ ដែលរាប់ទាំងប្រតិកម្មអាឡាក់ស៊ីទៅនឹងជាតិជ័រ (latex)។*

ទារកដែលមានបញ្ហាខ្សោយប្រព័ន្ធស៊ាំធ្ងន់ធ្ងរ (SCID)មិនគួរទទួលថ្នាំវ៉ាក់សាំងទេ។

ទារកដែលមានបញ្ហាស្ទះពោះវៀនធំ ដែលហៅថា "ជំងឺពោះវៀនលូនចូលគ្នា" មិនគួរទទួលថ្នាំវ៉ាក់សាំងជំងឺរាគដោយសារមេរោគរ៉ូតាទេ។

ទារកដែលមានជំងឺកម្រិតស្រាល អាចទទួលថ្នាំវ៉ាក់សាំង។ ទារកដែលមានជំងឺកម្រិតមធ្យម ឬធ្ងន់ធ្ងរ គួររង់ចាំ រហូតទាល់តែពួកគេជាសះស្បើយវិញ។ នេះរួមបញ្ចូលទាំងទារកដែលមានរោគរាគ ឬក្អួតកម្រិតមធ្យម ឬធ្ងន់ធ្ងរ។

សូមឆែកជាមួយនឹងវេជ្ជបណ្ឌិតរបស់លោកអ្នក ប្រសិនបើប្រព័ន្ធស៊ាំរបស់កូនលោកអ្នកចុះខ្សោយ ដោយសារតែ៖

- មានមេរោគអេដស៍/ជំងឺអេដស៍ ឬជំងឺផ្សេងទៀតដែលប៉ះពាល់ដល់ប្រព័ន្ធស៊ាំ
- ការព្យាបាលដោយប្រើថ្នាំ ដូចជាថ្នាំស្តេរ៉ូយ
- ជំងឺមហារីក ឬការព្យាបាលជំងឺមហារីកដោយកាំរស្មីអេច ឬថ្នាំ

## 4 ហានិភ័យកើតប្រតិកម្មថ្នាំវ៉ាក់សាំង

ថ្នាំវ៉ាក់សាំង ដូចថ្នាំណាក៏ដោយ អាចមានផលរំខាន។ ជាធម្មតា ផលរំខានទាំងនេះ មានកម្រិតស្រាល ហើយបាត់ទៅវិញដោយខ្លួនឯង។ ប្រតិកម្មធ្ងន់ធ្ងរក៏អាចកើតឡើងផងដែរ ប៉ុន្តែប្រតិកម្មទាំងនេះកម្រនឹងកើតឡើង។

មនុស្សភាគច្រើន ដែលទទួលថ្នាំវ៉ាក់សាំងជំងឺរាគដោយសារមេរោគរ៉ូតា ពុំមានបញ្ហាជាមួយនឹងថ្នាំវ៉ាក់សាំងទេ។ ប៉ុន្តែ បញ្ហាមួយចំនួនមានជាប់ពាក់ព័ន្ធនឹងថ្នាំវ៉ាក់សាំងជំងឺរាគដោយសារមេរោគរ៉ូតា៖

**បញ្ហាស្រាល**ក្រោយពីចាក់ថ្នាំវ៉ាក់សាំងជំងឺរាគដោយសារមេរោគរ៉ូតា៖

- ទារកអាចមានរោគរាគ ឬក្អួត ដែលកើតឡើងបណ្តោះអាសន្នកម្រិតស្រាល ឬធ្វើឲ្យមិនសុខស្រួល បន្ទាប់ពីចាក់ថ្នាំវ៉ាក់សាំងជំងឺរាគដោយសារមេរោគរ៉ូតា។

U.S. Department of Health and Human Services
Centers for Disease Control and Prevention

**បញ្ហាធ្ងន់ធ្ងរ**ក្រោយពីចាក់ថ្នាំវ៉ាក់សាំងជំងឺរាគដោយសារមេរោគរ៉ូតា៖

- ជំងឺពោះវៀនលូនចូលគ្នា គឺជាអាការៈស្ទះពោះវៀនធំ ដែលត្រូវព្យាបាលនៅមន្ទីរពេទ្យ ហើយអាចត្រូវធ្វើការវះកាត់។ វាកើតឡើង "តាមធម្មជាតិ" លើទារកមួយចំនួន នៅសហរដ្ឋអាមេរិក រៀងរាល់ឆ្នាំ ហើយជាធម្មតា គេមិនដឹងពីមូលហេតុទេ។

  ក៏មានហានិភ័យកម្រិតទាប ដែលអាចកើតជំងឺពោះវៀនលូនចូលគ្នាផងដែរ ដោយសារចាក់ថ្នាំវ៉ាក់សាំងជំងឺរាគដោយសារមេរោគរ៉ូតា ជាធម្មតាក្នុងរយៈពេលមួយសប្តាហ៍ បន្ទាប់ពីដូសថ្នាំវ៉ាក់សាំងទី1 ឬទី2 ។ ហានិភ័យបន្ថែម ត្រូវបានប៉ាន់ប្រមាណថា មានចំពោះទារកអាមេរិកប្រហែល 1 នាក់ ក្នុងចំណោម 20,000 នាក់ ទៅ 1 នាក់ ក្នុងចំណោម 100,000 នាក់ ដែលទទួលថ្នាំវ៉ាក់សាំងជំងឺរាគដោយសារមេរោគរ៉ូតា។ វេជ្ជបណ្ឌិតរបស់លោកអ្នកអាចផ្តល់ព័ត៌មានបន្ថែមដល់លោកអ្នក។

**បញ្ហាដែលអាចកើតឡើង បន្ទាប់ពីចាក់ថ្នាំវ៉ាក់សាំង៖**

- ថ្នាំណាក៏ដោយ អាចបង្កប្រតិកម្មអាឡាក់ស៊ីធ្ងន់ធ្ងរ។ ប្រតិកម្មអាឡាក់ស៊ីទាំងនេះ ដោយសារតែថ្នាំវ៉ាក់សាំង គឺជាបញ្ហាកម្រ ដែលតាមការប៉ាន់ប្រមាណ មានតិចជាង 1 ក្នុងមួយលានដូស ហើយនឹងកើតឡើង ក្នុងរយៈពេលប៉ុន្មាននាទី ទៅប៉ុន្មានម៉ោង បន្ទាប់ពីចាក់ថ្នាំវ៉ាក់សាំង។

ដូចថ្នាំផ្សេងទៀតដែរ ថ្នាំវ៉ាក់សាំងកម្រនឹងបង្ករបួសធ្ងន់ធ្ងរ ឬធ្វើឲ្យស្លាប់បាត់បង់ជីវិតណាស់។

សុវត្ថិភាពនៃថ្នាំវ៉ាក់សាំង តែងតែស្ថិតក្រោមការតាមដាន។ សម្រាប់ព័ត៌មានបន្ថែម សូមចូលទៅ៖ **www.cdc.gov/vaccinesafety/**

## 5 ចុះបើមានបញ្ហាធ្ងន់ធ្ងរ?

**តើខ្ញុំគួរប្រយ័ត្នចំពោះអ្វីខ្លះ?**

ចំពោះ **ជំងឺពោះវៀនលូនចូលគ្នា** សូមរកសញ្ញាបង្ហាញពីការឈឺពោះជាមួយនឹងការស្រែកយំខ្លាំងៗ។ នៅពេលដំបូង អាការៈទាំងនេះអាចបង្កកើតមានរយៈពេលតែប៉ុន្មាននាទី ហើយកើតឡើង និងបាត់ទៅវិញច្រើនដង ក្នុងរយៈពេលមួយម៉ោង។ ទារកអាចទាញជើងរបស់ខ្លួនឡើងលើដើមទ្រូង។

ទារករបស់លោកអ្នកក៏អាចក្អួតច្រើនដង ហើយមានឈាមក្នុងលាមក ហើយអាចហាក់បីដូចជាចុះខ្សោយកម្លាំង ឬឆាប់ខឹង។ ជាធម្មតា សញ្ញាទាំងនេះនឹងកើតឡើង ក្នុងអំឡុងសប្តាហ៍ទីមួយ បន្ទាប់ពីដូសថ្នាំវ៉ាក់សាំងជំងឺរាគដោយសារមេរោគរ៉ូតាដូសទី 1 ឬ ទី 2 ប៉ុន្តែ សូមពិនិត្យរកសញ្ញាទាំងនេះ នៅពេលណាក៏ដោយ បន្ទាប់ពីចាក់ថ្នាំវ៉ាក់សាំង។

សូមប្រយ័ត្នចំពោះអ្វីដែលធ្វើឲ្យលោកអ្នកព្រួយបារម្ភ ដូចជាសញ្ញាបង្ហាញពីប្រតិកម្មអាឡាក់ស៊ីធ្ងន់ធ្ងរ គ្រុនក្តៅខ្លាំង ឬឥរិយាបថខុសធម្មតា។

សញ្ញាបង្ហាញពី**ប្រតិកម្មអាឡាក់ស៊ីធ្ងន់ធ្ងរ** អាចរួមបញ្ចូលកន្ទួល ហើមមុខ និងបំពង់ក ពិបាកដកដង្ហើម ចង្វាក់បេះដូងញាប់ វិលមុខ និងកម្លាំងចុះខ្សោយ។ បញ្ហាទាំងនេះនឹងចាប់ផ្តើមកើតឡើងរយៈពេលប៉ុន្មាននាទីទៅប៉ុន្មានម៉ោងប៉ុណ្ណោះបន្ទាប់ពីការចាក់ថ្នាំវ៉ាក់សាំង។

**តើខ្ញុំគួរធ្វើអ្វីខ្លះ?**

ប្រសិនបើលោកអ្នកគិតថា វាជា **ជំងឺពោះវៀនលូនចូលគ្នា** សូមទូរស័ព្ទទៅវេជ្ជបណ្ឌិតភ្លាមៗ។ ប្រសិនបើលោកអ្នកមិនអាចទាក់ទងវេជ្ជបណ្ឌិតរបស់លោកអ្នកបាន សូមយកទារករបស់លោកអ្នកទៅកាន់មន្ទីរពេទ្យ។ សូមប្រាប់ពួកគេ នៅពេលទារករបស់លោកអ្នកទទួលថ្នាំវ៉ាក់សាំងជំងឺរាគដោយសារមេរោគរ៉ូតា។

ប្រសិនបើលោកអ្នកគិតថា វាគឺជា**ប្រតិកម្មអាឡាក់ស៊ីធ្ងន់ធ្ងរ** ឬស្ថានការណ៍សង្គ្រោះបន្ទាន់ដទៃទៀតដែលមិនអាចរង់ចាំបាន សូមទូរស័ព្ទទៅ 9-1-1 ឬយកអ្នកជំងឺទៅកាន់មន្ទីរពេទ្យដែលជិតបំផុត។

បើមិនអញ្ចឹងទេ សូមទូរស័ព្ទទៅវេជ្ជបណ្ឌិតរបស់លោកអ្នក។

បន្ទាប់មក ប្រតិកម្មគួររាយការណ៍ទៅ Vaccine Adverse Event Reporting System (VAERS) (ប្រព័ន្ធរាយការណ៍ផលអាក្រក់នៃថ្នាំវ៉ាក់សាំង)។ វេជ្ជបណ្ឌិតរបស់លោកអ្នកអាចដាក់បញ្ជូនរបាយការណ៍នេះ ឬលោកអ្នកអាចរាយការណ៍ដោយផ្ទាល់តាមរយៈគេហទំព័រ VAERS នៅ **www.vaers.hhs.gov** ឬតាមរយៈហៅទូរស័ព្ទមក **1-800-822-7967**។

*VAERS មិនផ្តល់យោបល់វេជ្ជសាស្ត្រទេ។*

## 6 កម្មវិធីជាតិបង់សំណងរបួសដោយសារថ្នាំវ៉ាក់សាំង

National Vaccine Injury Compensation Program (VICP) (កម្មវិធីជាតិបង់សំណងរបួសដោយសារថ្នាំវ៉ាក់សាំង) គឺជាកម្មវិធីរបស់រដ្ឋសហព័ន្ធ ដែលបានបង្កើតឡើងដើម្បីបង់សងអ្នកទាំងឡាយដែលអាចរងរបួសដោយសារតែថ្នាំវ៉ាក់សាំងមួយចំនួន។

បុគ្គលដែលជឿជាក់ថា ខ្លួនអាចធ្លាប់រងរបួសដោយសារថ្នាំវ៉ាក់សាំងមួយ អាចធ្វើការសិក្សាអំពីកម្មវិធី និងអំពីការដាក់ពាក្យទាមទារសំណង ដោយទូរស័ព្ទមក **1-800-338-2382** ឬចូលទៅគេហទំព័រ VICP នៅ **www.hrsa.gov/vaccinecompensation**។ មានរយៈពេលកំណត់ សម្រាប់ការដាក់ពាក្យទាមទារសំណង។

## 7 តើខ្ញុំអាចសិក្សាបន្ថែមទៀតដោយរបៀបណា?

- សូមសួរវេជ្ជបណ្ឌិតរបស់លោកអ្នក។ គាត់អាចផ្តល់ឯកសារក្នុងកញ្ចប់ថ្នាំវ៉ាក់សាំង ឬប្រាប់ប្រភពព័ត៌មានផ្សេងដល់លោកអ្នក។
- សូមទូរស័ព្ទទៅក្រសួងសុខាភិបាលរដ្ឋ ឬនៅមូលដ្ឋានរបស់លោកអ្នក។
- ទាក់ទង Centers for Disease Control and Prevention (CDC) (មជ្ឈមណ្ឌលទប់ស្កាត់ និងបង្ការជំងឺឆ្លង):
  - ទូរស័ព្ទមកលេខ**1-800-232-4636 (1-800-CDC-INFO)** ឬ
  - ចូលទៅគេហទំព័រ CDC នៅ **www.cdc.gov/vaccines**

Vaccine Information Statement

Rotavirus Vaccine

02/23/2018 **Khmer**

42 U.S.C. § 300aa-26

Office Use Only

Translation provided by the Immunization Action Coalition